**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ......០៣ សរ........

# សារាចរ
# ស្តីពី
# ការរៀបចំយុទ្ធនាការ "ឆ្នាំទស្សនាកម្ពុជា ២០២៣"

ដើម្បីបង្កើនការផ្សព្វផ្សាយទេសចរណ៍ និងលើកកម្ពស់កិត្តិនាមរបស់ព្រះរាជាណាចក្រកម្ពុជា នាឱកាសដែលកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេម អាស៊ានប៉ារ៉ាហ្គេមឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យអនុវត្តនូវយុទ្ធនាការ "**ឆ្នាំទស្សនាកម្ពុជា ២០២៣**" (Visit Cambodia Year 2023) ក្រោមពាក្យស្លោក "**គ្រប់ថ្ងៃ គឺជាអច្ឆរិយភាព**" (Every Day Is A Wonder)។ យុទ្ធនាការ "**ឆ្នាំទស្សនាកម្ពុជា ២០២៣**" ត្រូវបានរៀបចំឡើងក្នុងគោលបំណង៖

**ទី១** - លើកកម្ពស់កិត្តិនាមទេសចរណ៍ "**កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយ ផ្តល់ភាពកក់ក្តៅ**" នៅលើទីផ្សារទេសចរណ៍ឱ្យកាន់តែខ្លាំងក្លាសំដៅទាក់ទាញភ្ញៀវទេសចរអន្តរជាតិឱ្យបានយ៉ាងតិច **៤លាននាក់** និងភ្ញៀវទេសចរក្នុងស្រុកឱ្យបានយ៉ាងតិច **១៥លាននាក់** នៅឆ្នាំ២០២៣។

**ទី២** - ផ្សារភ្ជាប់រវាងព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ និងយុទ្ធនាការ "**ឆ្នាំទស្សនាកម្ពុជា ២០២៣**" ដើម្បីបង្កើនឧត្តមភាពប្រកួតប្រជែងទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩។

ក្នុងន័យនេះ ដើម្បីឱ្យយុទ្ធនាការ "**ឆ្នាំទស្សនាកម្ពុជា ២០២៣**" ប្រព្រឹត្តទៅប្រកបដោយជោគជ័យ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម៖

១ - ក្រសួងទេសចរណ៍ ត្រូវសហការជាមួយនឹងបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដី បណ្តាអង្គការជាតិ អន្តរជាតិ សមាគម ដៃគូអភិវឌ្ឍ និងវិស័យឯកជនដែលកំពុងប្រតិបត្តិនៅលើវិស័យទេសចរណ៍ រួមគ្នាផ្សព្វផ្សាយយុទ្ធនាការ "**ឆ្នាំទស្សនាកម្ពុជា ២០២៣**" ដោយផ្សារភ្ជាប់នឹងយុទ្ធនាការ "**កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយ ផ្តល់ភាពកក់ក្តៅ**" ដោយរំលេចអំពីអត្តសញ្ញាណនៃប្រទេសកម្ពុជា ដែលជាគោលដៅទេសចរណ៍ប្រមូលផ្តុំដោយភាពទាក់ទាញទេសចរណ៍ដ៏អស្ចារ្យ និងការទទួលស្វាគមន៍ដ៏កក់ក្តៅ ឈរលើសសរស្តម្ភ សក្តានុពលទាំង ៤ នៃទេសចរណ៍កម្ពុជារួមមាន(**១**). បេតិកភណ្ឌ

វប្បធម៌ (២). អេកូទេសចរណ៍ (៣). ទេសចរណ៍ឆ្នេរ និង (៤). ភាពជាខ្មែរ ដែលអាចផ្តល់ជូនភ្ញៀវទេសចរនូវបទពិសោធ និងភាពប្លែកៗគ្នាជារៀងរាល់ថ្ងៃប្រកបដោយក្តីសប្បាយរីករាយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

២- ក្រសួងទេសចរណ៍ត្រូវសហការជាមួយនឹងគណៈកម្មាធិការរៀបចំការប្រកួតកីឡាស៊ីហ្គេមកម្ពុជា (CAMSOC) ដើម្បីជំរុញការផ្សព្វផ្សាយ និងការប្រើខ្លឹមសារ និងនិមិត្តសញ្ញាផ្សព្វផ្សាយ "**ឆ្នាំទស្សនាកម្ពុជា ២០២៣**" ដោយផ្សារភ្ជាប់ជាមួយនឹងនិមិត្តសញ្ញា "**ព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣**" ជាមួយរូបតំណាង "**បូរីនិងរំដួល**" ព្រមទាំងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឱ្យបានទូលំទូលាយនៅតាមក្រុមហ៊ុនអាកាសចរណ៍ ច្រកទ្វារអន្តរជាតិ តាមទីតាំងសាធារណៈសំខាន់ៗ មូលដ្ឋានអាជីវកម្មទេសចរណ៍ ស្ថាប័នរដ្ឋ ឯកជន ដៃគូពាក់ព័ន្ធនានា ប្រព័ន្ធផ្សព្វផ្សាយក្នុង និងក្រៅប្រទេស និងតាមស្ថានទូតកម្ពុជានៅក្រៅប្រទេស។

៣- ក្រសួងព័ត៌មានត្រូវរៀបចំកម្មវិធីផ្សព្វផ្សាយខ្លឹមសារនៃយុទ្ធនាការ "**ឆ្នាំទស្សនាកម្ពុជា ២០២៣**" ដោយផ្សារភ្ជាប់ជាមួយនឹងនិមិត្តសញ្ញា "**ព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣**" ដើម្បីបំផុសឱ្យសាធារណជន ជាពិសេសភ្ញៀវទេសចរជាតិនិងអន្តរជាតិយល់ដឹង និងចូលរួមក្នុងយុទ្ធនាការខាងលើកាន់តែផុសផុល និងទូលំទូលាយ។

៤- ក្រសួងទេសចរណ៍ត្រូវសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្ត និងវិស័យឯកជន ដើម្បីរៀបចំបង្កើតឱ្យមានជាព្រឹត្តិការណ៍កម្រិតអន្តរជាតិ ជាតិ និងកម្រិតមូលដ្ឋាន ស្របតាមចក្ខុវិស័យ "**មួយខែ យ៉ាងតិចមួយព្រឹត្តិការណ៍**" និង "**មួយរាជធានី ខេត្ត ក្រុង យ៉ាងតិចមួយព្រឹត្តិការណ៍**"។

៥- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវណែនាំដល់គ្រប់ឯកអគ្គរាជទូត អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេស ផ្សព្វផ្សាយអំពីយុទ្ធនាការនិងនិមិត្តសញ្ញា "**ឆ្នាំទស្សនាកម្ពុជា ២០២៣**" ដោយផ្សារភ្ជាប់ជាមួយនឹងនិមិត្តសញ្ញា "**ព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ ឆ្នាំ២០២៣ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣**" ឱ្យបានកាន់តែទូលំទូលាយ។

៦- ក្រុមការងាររាជរដ្ឋាភិបាល និងឯកជនដើម្បីស្តារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ត្រូវធ្វើជាអង្គភាពអន្តរស្ថាប័នសម្របសម្រួល ទាក់ទាញ និងសិក្សាផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជនដែលចុះបញ្ជីទទួលស្គាល់ដោយក្រសួងទេសចរណ៍អនុញ្ញាតឱ្យរៀបចំព្រឹត្តិការណ៍ទេសចរណ៍ម៉ាយ និងព្រឹត្តិការណ៍កីឡា ជាពិសេសក្នុងការបង្កើតកម្មវិធី "**យើងជាម្ចាស់ផ្ទះ**" ក្រោមពាក្យស្លោក "**កីឡានិងព្រឹត្តិការណ៍ទេសចរណ៍ម៉ាយ**" (Sport and MICE)។

៧- ក្រសួងទេសចរណ៍ត្រូវសហការជាមួយនឹងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីខិតខំជំរុញបង្កើនភាពជាដៃគូ និងជំរុញការផ្លាស់ប្តូរបទពិសោធទេសចរណ៍ជាមួយប្រទេសជិតខាង រួមមានប្រទេសថៃ វៀតណាម និងឡាវ ជាពិសេសតាមរយៈការរៀបចំកញ្ចប់ទស្សនកិច្ច និងផ្សព្វផ្សាយរួមគ្នា ក្រោមប្រធានបទ "**ប្រទេសពីរ គោលដៅមួយ**" និង "**ប្រទេសបី គោលដៅមួយ**" ក៏ដូចជាសហការរៀបចំកញ្ចប់ទស្សនកិច្ចមុននិងក្រោយ ផ្សារភ្ជាប់នឹងព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ និងព្រឹត្តិការណ៍ទេសចរណ៍ធំៗផ្សេងទៀតរបស់កម្ពុជា។

៨- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវសហការជាមួយនឹងក្រសួងទេសចរណ៍ក្នុងការផ្សព្វផ្សាយគោលនយោបាយទិដ្ឋាការពិសេសសម្រាប់យុទ្ធនាការ "**ឆ្នាំទស្សនាកម្ពុជា ២០២៣**"។

៩- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវបន្តបំផុសយុទ្ធនាការអប់រំសង្គម "**មានអ្វីលើសពីការប្រកួតកីឡា**" (Beyond the Games) របស់សហភាពសហព័ន្ធយុវជនកម្ពុជា ដើម្បីបង្កើនការយល់ដឹងអំពីបច្ច័យជាវិជ្ជមាននៃការធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេមនិងអាស៊ានប៉ារ៉ាហ្គេមដែលចូលរួមផ្សព្វផ្សាយទាក់ទាញទេសចរនៅកម្ពុជា។

១០- ក្រុមហ៊ុនអាកាសចរណ៍ជាតិ "**កម្ពុជាអង្គរអ៊ែរ**" ត្រូវប្រើនិមិត្តសញ្ញា "**ឆ្នាំទស្សនាកម្ពុជា ២០២៣**" ផ្សារភ្ជាប់ជាមួយមធ្យោបាយផ្សព្វផ្សាយរបស់ខ្លួន និងលើកទឹកចិត្តឱ្យមានការប្រើនិមិត្តសញ្ញាយុទ្ធនាការនេះនៅលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ជាតិ និងក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិហោះចូលកម្ពុជា។

១១- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវប្រើនិមិត្តសញ្ញា "**ឆ្នាំទស្សនាកម្ពុជា ២០២៣**" ដូចមានចែងក្នុងឧបសម្ព័ន្ធនៃសារាចរនេះនៅក្នុងគ្រប់កម្មវិធី និងព្រឹត្តិការណ៍ជាតិនិងអន្តរជាតិនៅក្នុងប្រទេសកម្ពុជា រួមទាំងព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២។

១២- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវជំរុញការផ្សព្វផ្សាយនិងលើកទឹកចិត្តដល់វិស័យឯកជន និងភ្ញៀវទេសចរក្នុងការស្វែងយល់ពីអច្ឆរិយភាពជារៀងរាល់ថ្ងៃសម្រាប់ការទស្សនាកម្ពុជាឆ្នាំ២០២៣ ដើរស្របក្រោមយុទ្ធនាការទំនាក់ទំនងសាធារណៈជាសារខ្លីៗ ជាអាទិ៍ **(១)**. គ្រប់ថ្ងៃគឺជាអច្ឆរិយភាព (Every Day is a wonder), **(២)**. គ្រប់ទេសភាពគឺជាអច្ឆរិយភាព (Every View is a wonder), **(៣)**. គ្រប់ពេលគឺជាអច្ឆរិយភាព (Every Moment is a wonder), **(៤)**. គ្រប់រសជាតិគឺជាអច្ឆរិយភាព (Every Flavour is a wonder), **(៥)**. គ្រប់បទពិសោធគឺជាអច្ឆរិយភាព (Every Experience is a wonder), **(៦)**. គ្រប់ថ្ងៃរះគឺជាអច្ឆរិយភាព (Every Sunrise is a wonder), **(៧)**. គ្រប់ជំនួបគឺជាអច្ឆរិយភាព (Every Encounter is a wonder), **(៨)**. គ្រប់ការស្វាគមន៍គឺជាអច្ឆរិយភាព (Every Welcome is a wonder), **(៩)**. គ្រប់ប្រាសាទគឺជាអច្ឆរិយភាព (Every Temple is a wonder) **(១០)**. គ្រប់កោះគឺជាអច្ឆរិយភាព (Every Island is a wonder)។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។ ៕

ថ្ងៃព្រហស្បតិ៍ ៤កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃសារាចរលេខ....០៣.សរ.........ចុះថ្ងៃទី.២៣....ខែ...កុម្ភៈ.......ឆ្នាំ២០២៣**

**ស្តីពីការរៀបចំយុទ្ធនាការ "ឆ្នាំទស្សនាកម្ពុជា ២០២៣"**

Visit Cambodia

2023

Every day is a Wonder

**KINGDOM OF CAMBODIA**

**NATION RELIGION KING**

Unofficial Translation

ROYAL GOVERNMENT OF CAMBODIA
No. 03 SR

# Circular
# On
# Implementing the "Visit Cambodia Year 2023" Campaign

In order to increase tourism promotions and enhance the reputation of the Kingdom of Cambodia on the occasion that **Cambodia is the host of the 32nd SEA Games and the 12th ASEAN Para Games 2023,** the Royal Government set out to implement the "**Visit Cambodia Year 2023**" campaign under the slogan of "**Every Day Is a Wonder**". The **"Visit Cambodia Year 2023"** campaign is conducted in the following objectives:

**(1)**. To strongly promote the tourism reputation of "**Cambodia: Kingdom of Wonder - Feel the Warmth**" in the markets with the purpose of attracting at least **4 million** international tourists and at least **15 million** domestic tourists in 2023.

**(2)**. To connect the 32nd SEA Games and the 12th ASEAN Para Games with the **"Visit Cambodia Year 2023"** campaign to increase the excellence of Cambodia's tourism competitiveness after the COVID-19 crisis.

In this regard, in order to the **"Visit Cambodia Year 2023"** campaign to be successful, the Royal Government would like to set out the following recommendations:

**1)** The Ministry of Tourism must cooperate with ministries, institutions, local authorities, national and international organizations, associations, development partners and the private sector operating in the tourism sector to promote **"Visit Cambodia Year 2023"** campaign in connection with the "**Cambodia: Kingdom of Wonder Feel the - Warmth**" campaign shall highlight the identity of Cambodia as a tourism destination combined with wonderful tourist attractiveness and a warm welcome based on the **four potential pillars** of Cambodia's tourism, including **(1). Cultural heritage, (2). Ecotourism, (3). Cambodia's Bay and (4). Cambodianess** which can provide

tourists with a variety of experience and differences every day delightedly through a wide range of media.

2) The Ministry of Tourism must cooperate with The Cambodia SEA Games Organizing Committee (CAMSOC) to promote and use of content and promotion logo of the "**Visit Cambodia Year 2023**" in conjunction with the logo of **"the 32nd SEA Games and the 12th ASEAN Para Games 2023"** with the mascot "**Borey and Rumduol**" and Angkor Sangkranta event in a wide range of airlines, international gates, in major public places, tourism businesses, public and private institutions, stakeholders, local and foreign medias and Cambodian embassies abroad, etc.

3) The Ministry of Information must organize a program to disseminate the content of the "**Visit Cambodia Year 2023**" campaign in conjunction with the logo of **"the 32nd SEA Games and the 12th ASEAN Para Games 2023"** to inspire the public, especially national and international tourists to understand and participate in the above campaign more revitalized and comprehensive.

4) The Ministry of Tourism must cooperate with relevant ministries and institutions, Capital-Provincial Tourism Development Committee and the private sector to organize international, national and local events in line with the vision of **"at least one month per event"** and **"at least one capital/ province/city per event"**.

5) The Ministry of Foreign Affairs and International Cooperation shall instruct all Ambassadors, Consulate General and Honorary Consulates of the Kingdom of Cambodia abroad to promote the campaigns **"Visit Cambodia Year 2023"** in conjunction with the logo of **"the 32nd SEA Games and the 12th ASEAN Para Games 2023"** more broadly.

6) Government and private working groups to recover and promote tourism during and after the COVID-19 crisis as an inter-institutional entity which facilitates, attracts and encourages to private companies registered and recognized by The Ministry of Tourism, allowing them to organize Sports and MICE event, especially establish a program "**We Are the Host**" under the slogan of "**Sports and MICE**".

7) The Ministry of Tourism must cooperate with The Ministry of Foreign Affairs and International Cooperation to enhance partnerships and promote the exchange of tourism experiences with neighbouring countries as Thailand, Vietnam and Laos through the organization of joint tour packages and promotions under the theme of "**Two Countries, One Destination**" and "**Three Countries, One Destination**" as well as prepare Pre & Post-event packages to attract visitors and fans in connection with the 32nd SEA Games and the 12th ASEAN Para Games and other major tourism events of Cambodia.

8) The Ministry of Foreign Affairs and International Cooperation must cooperate with The Ministry of Tourism to promote of special Visa Policies for "**Visit Cambodia Year 2023**" Campaign.

9) All relevant ministries, institutions and units must continue to inspire social education "**Beyond the Games**" campaigns of the Union of Youth Federations of Cambodia to increase awareness of the positive consequences of hosting a major sporting SEA Games and ASEAN Para Games event to participate in promoting and attracting tourists to Cambodia.

10) **"Cambodia Angkor Air"** must use the "**Visit Cambodia Year 2023**" logo in connection with media and encourage the use of this campaign logo on the aircraft of national and international airlines flying to Cambodia.

11) All relevant ministries, institutions and units must use logo **"Visit Cambodia Year 2023"** logo as stated in the appendix of this circular in all national and international programs and events in Cambodia, including the 32nd SEA Games and the 12th ASEAN Para Games.

12) All relevant ministries, institutions and units must promote and encourage to private sector and tourists to be aware of everyday wonders for visiting Cambodia in 2023 under public relation campaigns through short messages such as: (1). Every Day is a Wonder, (2). Every View is a Wonder, (3). Every Moment is a Wonder, (4). Every Flavour is a Wonder, (5). Every Experience is a Wonder, (6). Every Sunrise is a Wonder, (7). Every Encounter is a Wonder, (8). Every Welcome is a Wonder, (9). Every Temple is a Wonder, and (10). Every Island is a Wonder.

Received this circular, all ministries, institutions and administrative capitals and provinces must implement it effectively and with a high sense of responsibility.

Phnom Penh, on 23rd February 2023

**Prime Minister**

(Stamped and Signed)

**Samdech Akka Moha Sena Padei Techo Hun Sen**

Receiving Place:

- Ministry of the Royal Palace
- General Secretariat of the Constitution Council
- General Secretariat of the Senate
- General Secretariat of the National Assembly
- Cabinet of Samdech Akka Moha Sena Padei Techo Prime Minister
- Cabinet of Samdech, His/Her Excellency Deputy Prime Ministers
- All Ministries and Institutions
- Capital and Provincial Administration
- Royal Gazette
- Chronological documents

**Annex of Circular No. 03 SR, dated on 23rd February 2023**

**On**

**Implementing the "Visit Cambodia Year 2023" Campaign**

Visit Cambodia

2023

Every day is a Wonder